**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៤ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពគណៈកម្មការការពារអង្គជំនុំជម្រះវិសាមញ្ញ

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតអោយមានអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់ក្តីអតីតមេដឹកនាំខ្មែរក្រហម
- បានឃើញកិច្ចព្រមព្រៀងស្តីពីការជំនុំជំរះក្តីអតីតមេដឹកនាំខ្មែរក្រហមរវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣
- បានឃើញសេចក្តីសំរេចលេខ១៣ សសរ ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មការដឹកនាំការងារធានាសន្តិសុខសំរាប់កិច្ចដំណើរការជំនុំជំរះក្តីអតីតមេដឹកនាំខ្មែរក្រហម
- យោងតាមការចាំបាច់ និងតាមសំណើរបស់គណៈកម្មការការពារអង្គជំនុំជំរះវិសាមញ្ញ (គ.ក.អ.វ)

## សំរេច

**ប្រការ ១ :** រៀបចំកែសំរួលសមាសភាព គ.ក.អ.វ មួយចំនួនដែលមានចែងនៅក្នុងប្រការ១ នៃ

សេចក្តីសំរេចលេខ ១៣ ស.ស.រ ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៤ ដូចខាងក្រោម :

- ប្រគល់ភារកិច្ចជូន ឯកឧត្តម ឧត្តមសេនីយ៍ឯក **គៀង សាវុធ** អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ ជាអនុប្រធាន គ.ក.អ.វ ជំនួសឯកឧត្តម **នៅ សំ** ។
- ប្រគល់ភារកិច្ចជូន ឯកឧត្តម **ឌុច សុន** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ជាសមាជិក គ.ក.អ.វ ជំនួសឯកឧត្តម **អ៊ិច សារូ** ។
- ឯកឧត្តម **ងួ គីមឡេង** អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក គ.ក.អ.វ ។

ប្រការ ២ : ប្រធានគណៈកម្មការការពារអង្គជំនុំជំរះវិសាមញ្ញ (គ.ក.អ.វ) មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ។

ប្រការ ៣ : សេចក្តីសំរេចនេះ មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ស ៥៦

ហ៊ុន សែន